**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិ**

**រៀបចំបុណ្យជាតិ-អន្តរជាតិ**

លេខៈ..០៤/២០២៦..............គ.ជ.ប.អ.

# ផែនការណែនាំ

## ស្ដីពី

## ការរៀបចំព្រះរាជពិធីច្រត់ព្រះនង្គ័ល ឆ្នាំ២០២៦

ព្រះរាជពិធីច្រត់ព្រះនង្គ័ល ជាព្រះរាជប្បវេណីដ៏មានសារសំខាន់ ក្នុងបណ្ដាព្រះរាជពិធីបុណ្យទ្វាទសមាស ប្រចាំឆ្នាំ ដោយចាត់ទុកជាវប្បមង្គលមួយដ៏ប្រសើររបស់ប្រជារាស្ត្រខ្មែរ ដែល**ព្រះមហាក្សត្រ** គ្រប់ព្រះអង្គ តែងដឹកនាំប្រារព្ធធ្វើពុំដែលខកខានតាំងពីបុរាណកាលរៀងមក ជាក់ស្ដែងកាលពីសម័យសង្គមរាស្ត្រនិយម **ព្រះករុណាព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតា ឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ "ព្រះបរមរតនកោដ្ឋ"** កាលព្រះអង្គមានព្រះជន្មគង់នៅ និង **សម្ដេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្ដីថ្លៃថ្នូរ និងសុភមង្គល** ព្រះអង្គសព្វព្រះរាជហឫទ័យយាងច្រត់ដោយផ្ទាល់ព្រះអង្គ នៅតាមបណ្ដា រាជធានី ខេត្តមួយចំនួនដូចជា រាជធានីភ្នំពេញ ខេត្តកណ្ដាល ខេត្តកំពង់ចាម ខេត្តស្វាយរៀង ខេត្តសៀមរាប ខេត្ត កំពង់ស្ពឺ និងខេត្តតាកែវជាដើម។ ចំណេរកាលក្រោយមក **ព្រះមហាក្សត្រ** ស្ដេចពុំបានយាងច្រត់ព្រះនង្គ័ល ដោយផ្ទាល់ព្រះអង្គឡើយ ព្រះអង្គតែងចាត់ព្រះរាជតំណាងយាងច្រត់ជំនួស តែព្រះអង្គស្ដេចយាងជាព្រះរាជាធិបតី ដ៏ខ្ពង់ខ្ពស់បំផុតក្នុងព្រះរាជពិធីនេះវិញ។

ព្រះរាជពិធីនេះ ប្រព្រឹត្តឡើងដើម្បីជាមង្គល ឧទ្ទិសដល់ការចាប់ផ្ដើមរដូវធ្វើស្រែចម្ការ របស់ប្រជាកសិករ និងបួងសួងដល់វត្ថុស័ក្ដិសិទ្ធិ ឱ្យបង្អុរទឹកភ្លៀងបរិបូណ៌តាមរដូវកាល បម្រើឱ្យវិស័យកសិកម្មគ្រប់ប្រភេទ ទទួលបាន ភោគផលខ្ពស់។

ព្រះរាជពិធីច្រត់ព្រះនង្គ័លឆ្នាំនេះ នឹងត្រូវប្រព្រឹត្តទៅនៅក្រុងព្រៃវែង ខេត្តព្រៃវែង រយៈពេល៤ថ្ងៃ គឺចាប់ ពីថ្ងៃ១-២-៣រោច ខែពិសាខ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០ ត្រូវនឹងថ្ងៃទី២-៣-៤ ខែឧសភា ឆ្នាំ២០២៦ ជាថ្ងៃប្រារព្ធ ហោមពិធី និងពិធីតាមរោងមណ្ឌលជាភារកិច្ចរបស់ក្រុមបាគូ ឯថ្ងៃអង្គារ ៤រោច ខែពិសាខ ត្រូវនឹងថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២៦ ប្រារព្ធព្រះរាជពិធីច្រត់ព្រះនង្គ័លជាផ្លូវការ។

ដើម្បីញ៉ាំងព្រះរាជពិធីច្រត់ព្រះនង្គ័ល ឱ្យប្រព្រឹត្តទៅយ៉ាងមហោឡារិក ស័ក្តិសមទៅនឹងអត្ថន័យ និងខ្លឹមសារ ដូចខាងលើ គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ សូមធ្វើការណែនាំដូចខាងក្រោម ៖

* <u>គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ រដ្ឋបាលខេត្តព្រៃវែង និងក្រសួងពាក់ព័ន្ធ</u>

សហការជាមួយក្រសួងព្រះបរមរាជវាំង រៀបចំព្រះរាជពិធីច្រត់ព្រះនង្គ័ល នៅក្រុងព្រៃវែង ខេត្តព្រៃវែង ឱ្យបាន មហោឡារិក ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ **ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ដោយមាន



វិថីឧកញ៉ា ឈុន កែងតិរវិថីព្រះស៊ីសុវត្ថិ ទល់មុខសាលសន្និសីទចតុមុខ រាជធានីភ្នំពេញ E-mail: nconif@gmail.com Phone: 012 912 265 / 097 97 69 111

ការយាង និងអញ្ជើញចូលរួមពីព្រះរាជវង្សានុវង្ស ថ្នាក់ដឹកនាំជាន់ខ្ពស់ជាតិ ព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល មន្ត្រីរាជការ សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ និស្សិត សិស្ស និងប្រជារាស្ត្រ តាមចំនួនកំណត់ជាក់ស្តែង ដើម្បីរួមគ្នាថែរក្សានូវព្រះរាជប្បវេណីពីបុរាណរបស់ **ព្រះមហាក្សត្រ** ឱ្យបានគង់វង្ស។

✷ <u>ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងរ៉ែ និងថាមពល ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្រសួងពាណិជ្ជកម្ម និងក្រសួងទេសចរណ៍</u>

ផ្តល់អនុសាសន៍ណែនាំដល់មន្ទីរជំនាញរៀបចំស្តង់ និងដាក់តាំងពិព័រណ៍ នៅក្រុងព្រៃវែង ខេត្តព្រៃវែង ដោយសហការល្អជាមួយគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ និងរដ្ឋបាលខេត្តព្រៃវែង។

✷ <u>ទីស្តីការគណៈរដ្ឋមន្ត្រី និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ</u>

ជួយបង្កលក្ខណៈងាយស្រួលដោះស្រាយសម្ភារៈ ថវិកា សម្រាប់បម្រើព្រះរាជពិធីនេះ ឱ្យប្រព្រឹត្តទៅបានសមស្របតាមគោលបំណង សំណូមពរ និងទាន់ពេលវេលា។

✷ <u>ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងរដ្ឋបាលខេត្តព្រៃវែង</u>

ចាត់ក្រុមសិល្បៈសម្តែងជូនប្រជារាស្ត្របានទស្សនាកម្សាន្ត អបអរសាទរព្រះរាជពិធីច្រត់ព្រះនង្គ័ល **នៅយប់ថ្ងៃអង្គារ ទី៥ ខែឧសភា ឆ្នាំ២០២៦** នៅក្រុងព្រៃវែង ខេត្តព្រៃវែង។

✷ <u>ក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ</u>

ជួយណែនាំដល់អង្គភាពក្រោមឱវាទ ឱ្យសហការការពាររក្សាសន្តិសុខ របៀបរៀបរយ សណ្តាប់ធ្នាប់សង្គម ចរាចរណ៍ ធានាសុវត្ថិភាពមុន-ក្រោយ និងក្នុងពេលប្រារព្ធព្រះរាជពិធីឱ្យបានល្អប្រសើរ និងចាត់កងកិត្តិយស ត្រែទ័ព ធ្វើព្រះរាជវន្ទនកិច្ចថ្វាយ **ព្រះមហាក្សត្រ** និងជូនវន្ទនកិច្ចចំពោះថ្នាក់ដឹកនាំជាន់ខ្ពស់ជាតិ។

✷ <u>ក្រសួងព័ត៌មាន</u>

ចាត់បណ្តាញវិទ្យុ ទូរទស្សន៍ជាតិ និងឯកជន ចុះធ្វើសកម្មភាពយកព័ត៌មាន និងធ្វើការផ្សាយផ្ទាល់ ព្រមទាំងណែនាំសមាគមទូរទស្សន៍កម្ពុជា ផ្សាយបន្តផ្ទាល់ពីទិដ្ឋភាព និងសកម្មភាពនៃការប្រារព្ធព្រះរាជពិធីច្រត់ព្រះនង្គ័ល។

✷ <u>អាជ្ញាធរមីនកម្ពុជា</u>

ស្រាវជ្រាវរាវរកគ្រឿងផ្ទុះគ្រប់ប្រភេទនៅកន្លែងប្រារព្ធព្រះរាជពិធី ដើម្បីធានាបានសុវត្ថិភាព។

✷ <u>រដ្ឋបាលខេត្តព្រៃវែង</u>

ត្រូវរៀបចំឱ្យមានតាំងពិព័រណ៍រូបភាពបង្ហាញពីនយោបាយទឹក ផលិតផលកសិកម្ម ដូចជា ស្រូវ ពោត សណ្តែក។ល។ សិប្បកម្មក្នុងស្រុក ព្រមទាំងវត្ថុសម្ភារៈ គ្រឿងបរិក្ខារកែច្នៃ និងសមិទ្ធផល៤៧ឆ្នាំ នៃការអភិវឌ្ឍលើគ្រប់វិស័យកន្លងមក ដែលខេត្តសម្រេចបាន ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាល ដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** អតីតជានាយករដ្ឋមន្ត្រី និង **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នាពេលបច្ចុប្បន្ន ដូចមានគូសក្រាហ្វិកខាងក្រោម ៖

-ដំណាក់កាលទី១ ឆ្នាំ១៩៧៩ ស្ថានភាព ស្ថិតលេខ ០ (សូន្យ)

-ដំណាក់កាលទី២ ឆ្នាំ២០០០ កម្រិតនៃការរីកចម្រើន ឆ្នាំកណ្តាល

-ដំណាក់កាលទី៣ ឆ្នាំ២០២៦ កម្រិតនៃការរីកចម្រើនជាបន្តបន្ទាប់ ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាល កន្លងមក

ណែនាំគ្រប់មន្ទីរ អង្គភាព គ្រប់ក្រុង ស្រុក ស្រាវជ្រាវផ្តិតរូបថតព្រះរាជសកម្មភាព **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា និង **សម្តេចព្រះមហាក្សត្រី ព្រះវររាជ**

**មាតាជាតិខ្មែរ** ស្តេចយាងចុះជួបប្រាស្រ័យសួរសុខទុក្ខព្រះសង្ឃ ប្រជារាស្ត្រ និងស្តេចយាងជាព្រះរាជាធិបតីដ៏ខ្ពង់ខ្ពស់បំផុត ក្នុងព្រះរាជពិធីនានា រៀបតាំងតាមស្តង់ពិព័រណ៍នីមួយៗ ដើម្បីបង្ហាញជូនប្រជារាស្ត្រ ភ្ញៀវកិត្តិយសជាតិ-អន្តរជាតិ និងអង្គទូតនានា បានទស្សនាស្វែងយល់ និងដើម្បីអបអរសាទរថ្វាយព្រះរាជសព្ទសាធុការពរបវរមហាប្រសើរ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត និង **សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត សូមមានព្រះរាជសុខភាពល្អបរិបូរណ៍ និងព្រះជន្មាយុយឺនយូរ។

ចាត់មន្ត្រីរាជការ សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ និស្សិត សិស្ស និងប្រជារាស្ត្រ ចូលរួមក្នុងព្រះរាជពិធីតាមចំនួនបានកំណត់ និងណែនាំគ្រប់មន្ទីរ អង្គភាព ក្រុង ស្រុក ឃុំ សង្កាត់ គ្រឹះស្ថានសិក្សា សាលារៀន រោងចក្រ សហគ្រាស ឱ្យតុបតែងលម្អ លើកទង់ជាតិ ទង់សាសនា ទង់ព្រះមហាក្សត្រ បដាពាក្យស្លោក និងណែនាំប្រជារាស្ត្រឱ្យលើកទង់ជាតិគ្រប់គេហដ្ឋាន។

✷ <u>គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន និងស្ថាប័ន</u>

ត្រូវតុបតែងលម្អ លើកទង់ជាតិ ទង់សាសនា ទង់ព្រះមហាក្សត្រ បដាពាក្យស្លោក ឱ្យបានស័ក្តិសម ដើម្បីអបអរសាទរ ព្រះរាជពិធីវប្បមង្គល។

✷ <u>រដ្ឋបាលរាជធានី ខេត្ត</u>

ចាត់ថ្នាក់ដឹកនាំចូលរួមក្នុងព្រះរាជពិធីច្រត់ព្រះនង្គ័ល នៅខេត្តព្រៃវែង តាមចំនួនកំណត់ និងណែនាំគ្រប់មន្ទីរ អង្គភាព ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ គ្រឹះស្ថានសិក្សា សាលារៀន រោងចក្រ សហគ្រាស និងគ្រប់គេហដ្ឋានប្រជារាស្ត្រឱ្យតុបតែងលម្អដោយលើកទង់ជាតិ ទង់សាសនា ទង់ព្រះមហាក្សត្រ បដាពាក្យស្លោកអបអរសាទរព្រះរាជពិធីវប្បមង្គលដ៏ឧត្តម។

គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ សង្ឃឹមនិងជឿជាក់ថាថ្នាក់ដឹកនាំ គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត នឹងយកចិត្តទុកដាក់ អនុវត្តនូវផែនការណែនាំនេះ ឱ្យបានសម្រេចលទ្ធផលល្អប្រសើរ៕

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២០ ខែ កុម្ភៈ ឆ្នាំ២០២៦

**ជ.គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ**

ប្រធាន

**សម្តេចមហាមន្ត្រី គុយ សុផល**

**ចម្លងជូន ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម ឧបនាយករដ្ឋមន្ត្រីប្រចាំការ
  "ដើម្បីជូនជ្រាប"
- គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត
  "ដើម្បីសហការអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

# ពាក្យស្លោក

## សម្រាប់ប្រើក្នុងព្រះរាជពិធីច្រត់ព្រះនង្គ័ល

## ថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២៦

១- អបអរសាទរ ព្រះរាជពិធីច្រត់ព្រះនង្គ័ល ថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២៦ នៅខេត្តព្រៃវែង

២- សូមថ្វាយព្រះពរ **ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា សូមមានព្រះរាជសុខភាពល្អ បរិបូរណ៍ និងព្រះជន្មាយុយឺនយូរ

៣- សូមថ្វាយព្រះពរ **សម្ដេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្ដីថ្លៃថ្នូរ និងសុភមង្គល** សូមមានព្រះរាជសុខភាពល្អ បរិបូរណ៍ និងព្រះជន្មាយុយឺនយូរ

៤- សូមថ្វាយព្រះរាជកុសល ព្រះវិញ្ញាណក្ខន្ធ **ព្រះករុណាព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតា ឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ "ព្រះបរមរតនកោដ្ឋ"** សូមបានយាងទៅសោយព្រះបរមសុខ ក្នុងសុគតិភព

៥- ជយោ! ព្រះរាជាណាចក្រកម្ពុជា

៦- ជាតិ សាសនា ព្រះមហាក្សត្រ

៧- ជយោ! នយោបាយ ឈ្នះ ឈ្នះ នាំមកនូវសន្តិភាព

៨- ជយោ! ទិវាសន្តិភាពនៅកម្ពុជា

៩- ជយោ! សន្តិភាព និងការអភិវឌ្ឍ

១០- ជយោ! សន្តិភាព ប្រជាធិបតេយ្យ និងអភិវឌ្ឍន៍

១១- ជយោ! សន្តិភាព និងការបង្រួបបង្រួមជាតិ

១២- មានសន្តិភាព ទើបមានការអភិវឌ្ឍប្រទេសជាតិ

១៣- ជយោ! រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

១៤- កសិកម្ម ជាមូលដ្ឋាននៃសេដ្ឋកិច្ចជាតិ

១៥- អភិវឌ្ឍវិស័យកសិកម្ម គឺអភិវឌ្ឍសង្គមជាតិ

១៦- កសិកម្មលូតលាស់ ជីវភាពប្រជាកសិករីកចម្រើន

១៧- រួមគ្នាស្ដារ និងអភិវឌ្ឍវិស័យកសិកម្ម

១៨- ព្រះរាជពិធីច្រត់ព្រះនង្គ័ល ជាវប្បមង្គលដ៏ឧត្ដម

១៩- អបអរសាទរ ព្រះរាជពិធីវប្បមង្គល